## រឿងទី២៖ កំណើតរបស់ព្រះយេស៊ូ

**ខគម្ពីរ៖ ម៉ាថាយ១:២៣**

«មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយព្រះនាមបុត្រនោះត្រូវហៅថា ឥម៉ាញូអែល» ដែលប្រែថា ព្រះអង្គទ្រង់គង់ជាមួយនឹងយើងខ្ញុំ»

កាលពីយូរលង់ណាស់មកហើយ មានស្ត្រីក្រមុំព្រហ្មចារីដ៏ស្រស់ស្អាតម្នាក់ឈ្មោះម៉ារី នាងរស់នៅភូមិណាសារ៉ែត ស្រុកអ៊ីស្រាអែល។

នាងម៉ារី ត្រូវជាគូដណ្ដឹងរបស់លោកយ៉ូសែប ដែលជាជាងឈើចិត្តល្អម្នាក់។

នៅគ្រានោះ ស្ដេចហេរ៉ូដដែលជាអ្នកគ្រប់គ្រងប្រទេស មិនជឿលើព្រះជាម្ចាស់នោះទេ ហើយប្រជាជនអ៊ីស្រាអែលនៅពេលនោះរស់នៅយ៉ាងលំបាកខ្លាំងណាស់ ដោយព្រោះពួកគេបានចេញឆ្ងាយពីព្រះជាម្ចាស់។ នៅយប់មួយ ពេលនាងម៉ារីកំពុងដេក ស្រាប់តែទេវតាកាព្រីអែលបានលេចមក។

"កុំខ្លាចអី ម៉ារីអើយ! ដ្បិតព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងនាងហើយ ព្រះអង្គគង់ជាមួយនាង។" ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកសណ្ឋិតលើនាង ហើយនាងនឹងមានគភ៌សម្រាលបានបុត្រាមួយ នាងត្រូវថ្វាយព្រះនាមថា "យេស៊ូ"។ ព្រះជាម្ចាស់នឹងតាំងបុត្រនោះឱ្យគ្រងរាជ្យលើបល្ល័ង្ករបស់ព្រះបាទដាវីឌ។"

ម៉ារីបាននិយាយថា៖ "ប៉ុន្តែនាងខ្ញុំមិនទាន់រៀបការផង ធ្វើដូចម្ដេចឱ្យខ្ញុំមានបុត្របាន?"

ទេវតាកាព្រីអែលបានតបថា៖ "បុត្រនោះមិនមែនជាកូនរបស់មនុស្សលោកឡើយ ប៉ុន្តែបុត្រនោះនឹងប្រសូតមកដោយព្រះចេស្ដារបស់ព្រះ! បុត្រនោះនឹងត្រូវបានគេហៅថាជាបុត្ររបស់ព្រះជាម្ចាស់។"

នៅពេលនោះ បើមានស្ត្រីក្រមុំណាមានកូនដោយមិនបានរៀបការ ជារឿងគួរឱ្យភ័យខ្លាចណាស់ ព្រោះនឹងត្រូវគេសម្លាប់ដោយចោលនឹងថ្ម។ ហើយម៉ារីក៏នឹងត្រូវយ៉ូសែបជាគូដណ្ដឹងបោះបង់ចោលផងដែរ។ ទោះបីជាដូច្នេះក៏ដោយ ក៏ម៉ារីសម្រេចចិត្តស្ដាប់បង្គាប់ព្រះក្នុងការបង្កើតបុត្រានោះខ្លួនមិនទាន់រៀបការក៏ដោយ ហើយនាងថែមទាំងបានសរសើរដំកើងនិងអរព្រះគុណព្រះយ៉ាងអស់ពីចិត្តទៀតផង។ មិនយូរប៉ុន្មាន នាងក៏មានគភ៌ស្របតាមពាក្យរបស់ទេវតា។ យ៉ូសែបដែលជាគូដណ្ដឹងរបស់ម៉ារី ជាមនុស្សសុភាព និងសុចរិត។

ក៏ប៉ុន្តែ គាត់ពិបាកទទួលយកណាស់ បន្ទាប់ពីបានដឹងថាម៉ារីមានគភ៌។

យ៉ូសែបបានគិតថាគាត់មិនអាចរៀបការជាមួយម៉ារីបានទេ ក៏បានសម្រេចចិត្តថា នឹងប្រាប់ដល់ម៉ារី។ ក៏ប៉ុន្តែ ទេវតាបានលេចមកក្នុងសុបិនរបស់គាត់។

"យ៉ូសែប ជាពូជពង្សដាវីឌអើយ! កុំឱ្យខ្លាចនឹងយកនាងម៉ារីធ្វើជាភរិយាឡើយ។ ម៉ារីនាងមានគភ៌ដោយព្រះវិញ្ញាណបរិសុទ្ធទេ។ ម៉ារីនឹងប្រសូតបានបុត្រមួយ ត្រូវថ្វាយព្រះនាមទ្រង់ថា «យេស៊ូ» បុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ឱ្យរួចពីបាប។" យ៉ូសែបបានរៀបការជាមួយនាងម៉ារីតាមសន្យា បន្ទាប់ពីបានឮពាក្យរបស់ទេវតា។

ប៉ុន្មានខែក្រោយមក លោកយ៉ូសែបត្រូវនាំម៉ារីដែលកំពុងមានទម្ងន់ ដើម្បីទៅបេថ្លេហិមជាស្រុកកំណើតគេ។

ពីព្រោះស្ដេចរ៉ូម៉ាំង បានចេញរាជបញ្ជាឱ្យប្រជារាស្ត្រទាំងអស់ត្រូវតែទៅស្រុកកំណើតរបស់ខ្លួន ដើម្បីធ្វើជំរឿន។

មេឃកាន់តែងងឹត ប៉ុន្តែម៉ារីនិងយ៉ូសែបមិនទាន់អាចរកកន្លែងសម្រាប់ស្នាក់នៅបានឡើយ។ ពីព្រោះនៅទីនោះមានមនុស្សមកច្រើនទៅហើយ។

អ្នកទាំងពីរមិនអាចរកកន្លែងស្នាក់នៅបាន ក៏បានចូលទៅក្នុងក្រោលរបស់សេះ។ នៅរាត្រីនោះ បុត្រតូចក៏បានប្រសូតមក។

បុត្រនោះគឺជាបុត្ររបស់ព្រះដែលយាងមកដើម្បីសង្គ្រោះរាស្ត្រទ្រង់ពីអំពើបាប គឺជា«ព្រះយេស៊ូគ្រិស្ទ»។



**សកម្មភាពទី១** សូមគិតពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



- ចូរសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(ម៉ាថាយ១:២៣)

# ហើយព្រះនាមបុត្រនោះត្រូវហៅថា អេម៉ាញូអែល

**សកម្មភាពទី២** ចូរផាត់ពណ៌រូបខាងក្រោម រួចកាត់បិទ។





រូបភាពរួចរាល់



សម្ភារៈ
កន្ត្រៃ, កូណើរទៀន, កាវ